**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

# កំណត់ហេតុ ស្តីពី
# កម្មវិធីពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល សិក្ខាសាលា ក្រុងព្រះសីហនុ និងខេត្តកោះកុង

ឆ្នាំពីរពាន់ប្រាំបី ខែ ឧសភា ថ្ងៃទី ០៨ វេលាម៉ោងប្រាំបី នៅក្រុងព្រះសីហនុ មានរៀបចំសិក្ខាសាលាមួយក្រោមអធិបតីភាពឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងមានការចូលរួមពីឯកឧត្តម ស្បោង សារ៉ាត់ អភិបាលរងក្រុងព្រះសីហនុ ដើម្បីពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់ អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិល។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស្បោង សារ៉ាត់ អភិបាលរងក្រុងព្រះសីហនុ បានធ្វើការស្វាគមន៍ចំពោះគណៈអធិបតី និងថ្លែងអំណរគុណ ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងពិភាក្សាផ្លាស់ប្តូរយោបល់លើកម្មវិធីសកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការ ជាមួយភ្នាក់ងារអនុវត្ត និងសង្គមស៊ីវិលដើម្បីផ្តល់នូវព័ត៌មាន និងចែករំលែកនូវបទពិសោធន៍ផ្សេងៗដល់មន្ត្រីរបស់ស្ថាប័នជំនាញនានា នៅតាមបណ្តាខេត្តឱ្យមានការយល់ដឹងកាន់តែប្រសើរឡើងថែមទៀតអំពីការកែទម្រង់ច្បាប់ និងតុលាការ ។ ឯកឧត្តមមានការចាប់អារម្មណ៍ផងដែរថា វិស័យកំណែទម្រង់ច្បាប់ និងតុលាការនេះជាអាទិភាពមួយដ៏ចាំបាច់បំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា យើងដែលត្រូវតែធ្វើជាបន្ទាន់ ហើយឯកឧត្តមសង្ឃឹមថា សហការីមកពីមន្ទីរ ស្ថាប័នជំនាញផ្សេងៗជុំវិញក្រុងព្រះសីហនុនឹងចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាក្នុងអង្គសិក្ខាសាលានេះ ។ ជាមួយគ្នានោះផងដែរ ឯកឧត្តមបានបង្ហាញនូវការយកចិត្តទុកដាក់យ៉ាងខ្លាំងក្នុងការអនុវត្តការងារនេះកំណែ ទម្រង់របស់ក្រុងព្រះសីហនុ ហើយឯកឧត្តមសង្ឃឹមថា សកម្មភាពកំណែទម្រង់របស់ក្រុងព្រះសីហនុ និងខេត្តកោះកុងនេះនឹងអាចដាក់បញ្ចូលទៅក្នុងផែនការសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការ របស់រាជរដ្ឋាភិបាលទាំងស្រុង ដើម្បីជំរុញការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងតុលាការអោយកាន់តែខ្លាំងឡើងថែមទៀត ។

ជាបន្ទាប់ ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានជម្រាបជូនអំពីការអភិវឌ្ឍគម្រោងដែលបានរៀបចំមកនេះ ទាក់ទងនឹងកម្មវិធីកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលជាវិស័យអាទិភាពមួយនៃយុទ្ធសាស្រ្តចតុកោណ ដែលមានសម្តេចអគ្គសេនាបតី តេជោ ហ៊ុន សែន ជាប្រមុខរាជរដ្ឋាភិបាលនោះ ត្រូវបានទទួលការឯកភាពអនុម័តលើឯកសារយុទ្ធសាស្រ្តកាលពីខែ មិថុនា ឆ្នាំ ២០០៣ ដោយគណៈរដ្ឋមន្រ្តី ។ យុទ្ធសាស្រ្តនេះឈរលើទស្សនាទានបួន ជាមូលដ្ឋានដែលបានដកស្រង់ចេញពីរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា គឺ៖

១-សិទ្ធិបុគ្គល

២-ប្រជាធិបតេយ្យសេរី

៣-ការបែងចែកអំណាចដាច់ពីគ្នា

៤-នីតិរដ្ឋ ។

ជាបន្ទាប់ ឯកឧត្តមប្រធានបានធ្វើការបង្ហាញជូនអង្គសិក្ខាសាលាអំពីដំណើរការនៃការកែទម្រង់ច្បាប់ និងតុលាការ និងការរៀបចំរចនាសម្ព័ន្ធនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលបានបង្កើតឡើងនៅថ្ងៃ ទី ២០ ខែ មិថុនា ឆ្នាំ ២០០២ ដោយមានឯកឧត្តម សុខ អាន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្រ្តីទីស្តីការគណៈរដ្ឋមន្ត្រី និងឯកឧត្តម ឌិត មន្ទី ប្រធានតុលាការកំពូលជាសហប្រធាន ។ ឯកឧត្តមបានបង្ហាញជូនអង្គប្រជុំអំពីអង្គភាពផ្សេងៗ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រពន្ធ័យុត្តិធម៌ ដែលរួមមានអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ (PCB) ដែលបានបង្កើតឡើងនៅថ្ងៃទី ១១ ខែ សីហា ឆ្នាំ ២០០២ និងអង្គភាពគ្រប់គ្រងគម្រោង ( PMU ) ដែលបានបង្កើតឡើងនៅ ថ្ងៃទី ២៦ ខែ ធ្នូ ឆ្នាំ ២០០២ ដើម្បីជួយអង្គភាពសម្របសម្រួលអចិន្ត្រៃយ៍ ក្នុងការបំពេញតួនាទីជាសេនាធិការ របស់ក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌។ ឯកឧត្តម បានជម្រាបជូនអង្គសិក្ខាសាលាអំពីសារៈសំខាន់ និងគោលដៅនៃកំណែទម្រង់ច្បាប់ និងតុលាការ ថាត្រូវបង្កើតនូវវិស័យច្បាប់ និងតុលាការមួយ ដែលអាចជឿទុកចិត្តបាន និងមានស្ថេរភាពសម្រាប់ទ្រទ្រង់គោលការណ៍ សិទ្ធិរបស់បុគ្គល ការបែងចែកអំណាចដាច់ពីគ្នា និងនីតិរដ្ឋនៅក្នុងលិទ្ធិប្រជាធិបតេយ្យសេរី តាមរយៈការលើកស្ទួយនូវការរីកចំរើនសេដ្ឋកិច្ចនាំមុខដោយវិស័យឯកជន ។

លោក តាំង ស៊ុនឡាយ ចៅក្រមតុលាការក្រុងព្រះសីហនុ តំណាងអោយលោកប្រធានតុលាការក្រុងព្រះសីហនុ បានលើកឡើងពីកំណែទម្រង់សំខាន់ៗរបស់រាជរដ្ឋាភិបាល ដែលក្នុងនោះមានកំណែទម្រង់ច្បាប់ និងតុលាការផងដែរ ។ ចាប់តាំងពីឆ្នាំ ២០០៣ មកស្ថាប័ននីតិបញ្ញាតិបានអនុម័តច្បាប់សំខាន់ៗ រហូតមកដល់ពេលនេះ មានក្រមធំចំនួនពីរបានអនុវត្តទូទាំងប្រទេស ដែលជាតម្រូវការលើវិស័យតុលាការនេះ ។ ជាមួយគ្នានោះដែរ លោកបានកោតសរសើរផងដែរថា ចាប់តាំងពីមានការកែទម្រង់ច្បាប់ និងតុលាការ តុលាការក្រុងព្រះសីហនុមានការរីកចំរើន និងប្រែប្រួលមុខមាត់ថ្មី

ជាច្រើនផងដែរ ។ ដើម្បីជាការចូលរួមក្នុងវិស័យតុលាការនេះ តុលាការក្រុងព្រះសីហនុបានចូលរួម បណ្តុះបណ្តាលដល់ ចៅក្រម ព្រះរាជអាជ្ញា និងក្រឡាបញ្ជីជាដើម ។

<u>បញ្ហាប្រឈមមុខ</u> ៖

- បញ្ហាធនធានមនុស្ស
- ក្រឡាបញ្ជីមានការខ្វះខាតច្រើនចំពោះខេត្តឆ្ងាយ ជាក់ស្តែងក្រឡាបញ្ជីមានចំនួនមិនដល់ដប់ នាក់ផង
- ទាក់ទងនឹងវិស័យហិរញ្ញវត្ថុ លោកលើកឡើងថា ក៏មានការលំបាកដែរ ទាក់ទិននឹងយន្តការ ដោះស្រាយវិវាទជាក់ស្តែងរឿងព្រហ្មទណ្ឌ ដែលត្រូវមានខ្ទង់ចំណាយថវិកាសម្រាប់ចុះធ្វើការស៊ើបអង្កេត ។ លោកចៅក្រមបានជម្រាបថា ថវិការបស់ក្រសួងសម្រាប់វិស័យ នេះមានតែ ០.៣ភាគរយប៉ុណ្ណោះ ។
- លោកបានស្នើសុំអោយមានសហប្រតិបត្តិល្អជាមួយស្ថាប័នជំនាញពាក់ព័ន្ធ និងអាជ្ញាធរទាំងអស់ ជាពិសេសបញ្ហាជួបប្រទៈដូចជា បញ្ហាធ្វើកោសល្យវិច្ច័យជាដើម ។

ឯកឧត្ដម ប៉ែន ប៊ុនឈា នាយករងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានធ្វើបទបង្ហាញ អំពីតារាងស្ថានភាពនៃការអនុវត្តកម្មវិធីសកម្មភាពកំណែទម្រង់ច្បាប់ និងតុលាការនៅកម្ពុជា ។ ឯកឧត្តមធ្វើ ការពន្យល់បង្ហាញតាមរយៈឯកសារចែកជូន និងតាមការបញ្ចាំងតាមស្លាយ ។

លោក ហ៊្វិត ហ៊ី ព្រះរាជអាជ្ញាតុលាការខេត្តកោះកុង បានស្នើសុំអោយចាត់តុលាការខេត្តកោះកុងនេះក្នុង គម្រោងតុលាការគំរូផងដែរ ព្រោះក្នុងគម្រោងឃើញមានតែបួនទីតាំងតែប៉ុណ្ណោះ ។

<u>បញ្ហាប្រឈមមុខ</u> ៖

- នៅក្នុងខេត្តកោះកុងនេះមានបញ្ហាដូចជា បញ្ហាអាគារតុលាការមានការលំបាក ព្រោះអាគារនេះ ស្ថិតនៅរួមជាមួយមន្ទីរដ៏ទៃទៀតដែរ
- ស្នើសុំអោយខាងថ្នាក់ខេត្តជួយសម្រួលកន្លែងអោយខាងតុលាការ ព្រោះមន្ទីរបរិស្ថានពុំសូវមានមនុស្សធ្វើការ និងមានព្រះរាជអាជ្ញាមកពីក្រុងព្រះសីហនុ មកបំពេញការងារនៅខេត្តកោះកុង ប៉ុន្តែមិនមានកន្លែងសម្រាប់បំពេញការងារទេ លោកក៏មានចម្ងល់ផងដែរថា តើពីមុនគេធ្វើការយ៉ាងដូចម្តេច បើខ្វះសព្វបែបយ៉ាងដូច្នេះ ? លោកបានជម្រាបថា លោកទើបតែផ្លាស់មកខេត្ត កំពង់ធំ
- ចំពោះធនធានខាងសម្ភារៈមានការខ្វះខាតច្រើនណាស់ ជាពិសេសបន្ទប់ដាក់វត្ថុតាងគ្មានកន្លែងរក្សាទុក និងកន្លែងធ្វើជាដើម
- បញ្ហាធនធានមនុស្សក៏មានការខ្វះខាតមិនខុសពីតុលាការដទៃទៀតនោះដែរ ។

ឯកឧត្តមអភិបាលរង ខេត្តកោះកុង បានមានមតិឆ្លើយតបទៅនឹងព្រះរាជអាជ្ញាថា ទាក់ទងនឹងកន្លែងធ្វើការយ៉ាងណាៗនោះ សូមអោយលោកព្រះរាជអាជ្ញាសួរនាំព្រះរាជអាជ្ញាមុន ។ ទាក់ទងនឹងសមត្ថកិច្ចនេះ ឯកឧត្តមបានផ្តល់ជាមតិយោបល់ថា លោកព្រះរាជអាជ្ញាអាចធ្វើការជួបជាមួយឯកឧត្តមអភិបាលខេត្តកោះកុង ឬជួបផ្ទាល់ជាមួយឯកឧត្តមអភិបាលរងក៏បានដែរ ។ ជាចុងក្រោយឯកឧត្តមបានស្នើសុំអោយខាងក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ពេលក្រោយបើមានការធ្វើសិក្ខាសាលាផ្សព្វផ្សាយទៀត សុំធ្វើយ៉ាងណាអោយមានរយៈពេលយូរជាងនេះ និងផ្សព្វផ្សាយច្បាប់អោយបានដល់ប្រជាពលរដ្ឋ ជាក់ស្តែងដូចច្បាប់ចរាចរជើងគោកជាដើម ។

ឯកឧត្តម សួង លាងហៃ បានមានប្រសាសន៍ថា បញ្ហាផ្ទៃក្នុងរបស់តុលាការខេត្តកោះកុងនេះ ឯកឧត្តម នឹងស្នើសុំអោយខាងតុលាការដោះស្រាយដោយផ្ទាល់ ព្រោះថា នេះជាបញ្ហាតូចតាចតែប៉ុណ្ណោះ ។

ទាក់ទងនឹងការបង្កើតតុលាការគំរូនេះ ឯកឧត្តមបានលើកពន្យល់ពីសាលាដំបូងក្រុងភ្នំពេញដែលពីមុនពិបាកស្មុគ្រស្មាញ ដូចជាគ្មានកន្លែងធ្វើការ សំណុំរឿងកកស្ទះច្រើនជាដើម ។ ហេតុនេះហើយបានជាប្រធានសាលាដំបូងក្រុងភ្នំពេញបានដាក់ចេញនូវយុទ្ធសាស្ត្រលុបបំបាត់បញ្ហាអស់ទាំងនេះ ហើយសាលាដំបូងនេះ ត្រូវបានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ចាត់ចូលក្នុងគម្រោងសាកល្បងតុលាការគំរូផងដែរ ។

ចំពោះបញ្ហាអាគារធ្វើបន្ទប់តំកល់វត្ថុតាង និងឯកសារផ្សេងៗ ឯកឧត្តមប្រធាននឹងលើកសំណើរជូនទៅថ្នាក់ដឹកនាំ ដូចជាក្រសួងយុត្តិធម៌ និងក្រុមប្រឹក្សាជាដើម ប៉ុន្តែបញ្ហាបន្ទាន់នៅចំពោះមុខនោះ ឯកឧត្តម បានស្នើអោយលោកព្រះរាជអាជ្ញាសហការជាមួយថ្នាក់ខេត្ត ដើម្បីធ្វើការដោះស្រាយបញ្ហាប្រឈមមុខនេះ ។

ចំណែកការអនុវត្តក្រមនីតិព្រហ្មទណ្ឌ ទាក់ទងនឹងមន្ត្រីនគរបាលយុត្តិធម៌ចូលកាន់តំណែង ហើយត្រូវធ្វើការស្បថស្បែសូមអោយលោកព្រះរាជអាជ្ញជួយធ្វើការសម្របសម្រួល ។

លោក ពុំ សិរីវុឌ្ឍន៍ អភិបាលរងខណ្ឌមិត្តភាព ក្រុងព្រះសីហនុ បានមានប្រសាសន៍ថា លោកសង្កេតឃើញសារព័ត៌មានបានសរសេរនូវរឿងប្រឌិតមិនពិត ដែលទាក់ទងនឹងការបង្ខូចកេរ្តិ៍ឈ្មោះថ្នាក់ដឹកនាំ ហេតុនេះលោកបានស្នើសុំអោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ បង្កើតច្បាប់មួយគឺ «ក្រមសីលធម៌នៃការសរសេរព័ត៌មាន» ដោយធ្វើការចងក្រងជាច្បាប់ ដើម្បីធ្វើការផ្សព្វផ្សាយដល់ប្រជាពលរដ្ឋ ។ ជាចុងក្រោយលោកបានសំណូមពរដល់ខាងអ្នកសារព័ត៌មានថា សរសេរទៅតាមវិជ្ជាជីវៈបានហើយ កុំបំភ្លៃការពិត ។

ឯកឧត្តម សួង លាងហៃ បានមានប្រសាសន៍ទាក់ទងនឹងសារព័ត៌មាននេះថា ក្រសួងមានច្បាប់សារព័ត៌មានស្រាប់ហើយ ប៉ុន្តែត្រូវធ្វើការកែសម្រួលបន្ថែម និងរង់ចាំកិច្ចសហការពីជំនាញឯកទ្វេស

បរទេសជួយដែរ ។ ហើយក្នុងរឿងសារព័ត៌មាននេះទៀតសោត ឯកឧត្តមក៏ពុំបានដឹងថាដល់ត្រង់ណាហើយទេ ព្រោះឯកឧត្តមផ្ទាល់មិនទាន់បានទាក់ទង ជាមួយសាម៉ីក្រសួងនៅឡើយទេ ។

លោក តាំង ស៊ុនឡាយ ទាក់ទងនឹងការផ្សព្វផ្សាយព័ត៌មានមិនពិតនោះ លោកបានមានប្រសាសន៍ថា បើតាមផ្លូវច្បាប់ យើងអាចធ្វើលិខិតស្នើអោយខាងអ្នកសរសេរព័ត៌មាននោះធ្វើការកែតម្រូវ ប្រសិនបើនៅតែមិនព្រមកែតម្រូវនោះ យើងត្រូវអោយខាងសារព័ត៌មានដដែលនោះ សរសេរជាលាយលក្ខ័អក្សរ « សូមទោស » ហើយបើនៅតែមិនព្រម ទៀត យើងត្រូវដាក់ប្ដឹងទៅតាមនីតិវិធីតុលាការតែម្តង ។

ជាចុងក្រោយ ឯកឧត្តមបានថ្លែងអំណរគុណចំពោះការយកចិត្តទុកស្តាប់ របស់ឯកឧត្តមអភិបាលខេត្ត និងឯកឧត្តម លោកដែលជាប្រធាន និងមន្ត្រីមន្ទីរជំនាញក្នុងក្រុងព្រះសីហនុ និងខេត្តកោះកុងទាំងមូល ដែលបានចូលរួមក្នុងអង្គសិក្ខាសាលាផ្សព្វផ្សាយនាថ្ងៃនេះ យ៉ាងជ្រាលជ្រៅ និងជូនពរប្រាំប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភានៈ ដល់អង្គសិក្ខាសាលាទាំងមូល ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ សីហា ឆ្នាំ២០០៨*

បានឃើញ និងឯកភាព
នាយករងអង្គភាពគ្រប់គ្រងគម្រោង

អ្នកធ្វើរបាយការណ៍

សួង លាងហៃ

សេង វ៉ាន់ដា ស៊ុន សិរីវុធ